**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ០៧០៦ ព.ណ.[illegible]

# សេចក្ដីប្រកាសព័ត៌មាន

## ស្ដីពីលទ្ធផលនៃសិក្ខាសាលាស្ដីពី "ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់៖ ផលបច្ច័យ បញ្ហាប្រឈម និងកំណើនសេដ្ឋកិច្ចនាពេលអនាគតសម្រាប់តំបន់អាស៊ីប៉ូស៊ីហ្វិកនិងអាស៊ាន"

ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនសាធារណជន អ្នកស្រាវជ្រាវ បញ្ញវន្ត វិស័យឯកជន និងបណ្ដាញសារព័ត៌មានឱ្យបានជ្រាបថា កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ វិទ្យាស្ថានបណ្ដុះបណ្ដាលពាណិជ្ជកម្មនិងស្រាវជ្រាវ (TTRI) នៃក្រសួងពាណិជ្ជកម្ម សហការជាមួយវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់តំបន់អាស៊ាននិងអាស៊ីបូព៌ា (ERIA) បានរៀបចំសិក្ខាសាលាអន្តរជាតិមួយលើប្រធានបទ "ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (អាសិប)៖ ផលបច្ច័យ បញ្ហាប្រឈម និងកំណើនសេដ្ឋកិច្ចនាពេលអនាគតសម្រាប់តំបន់អាស៊ីបូព៌ានិងអាស៊ាន" ក្រោមគណៈអធិបតីដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា និង ឯកឧត្តមសាស្ត្រាចារ្យ អ៊ីដេតូស៊ិ នីស៊ីមូរ៉ា ប្រធានវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់តំបន់អាស៊ាននិងអាស៊ីបូព៌ា។ អង្គសិក្ខាសាលានេះត្រូវបានធ្វើឡើងនៅសណ្ឋាគារ ហាយ៉ាតរីជិនស៊ី ដោយមានការចូលរួមដោយផ្ទាល់ និងតាមប្រព័ន្ធវីដេអូហ្ស៊ូម (Zoom) ពីឯកឧត្តម-លោកជំទាវតំណាងក្រសួង-ស្ថាប័ន ឯកឧត្តម-លោកជំទាវតំណាងស្ថានទូតប្រចាំនៅកម្ពុជា អ្នកសិក្សាស្រាវជ្រាវ និងវិស័យឯកជន សរុបប្រមាណ ២០០នាក់។ ក្នុងអង្គសិក្ខាសាលានេះ ក៏មានការសម្ពោធដាក់ឱ្យប្រើប្រាស់សៀវភៅស្ដីពីកិច្ចព្រមព្រៀងអាសិប (RCEP) ក្រោមគណៈអធិបតីដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា និងឯកឧត្តមសាស្ត្រាចារ្យ**ប្រធានវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់តំបន់អាស៊ាននិងអាស៊ីបូព៌ា។

អង្គសិក្ខាសាលានេះ មានការធ្វើបទបង្ហាញចំនួនបី និងកិច្ចពិភាក្សាចំនួនមួយ ធ្វើឡើងដោយអ្នកជំនាញជាតិនិងអន្តរជាតិ ព្រមទាំងមន្ត្រីជាន់ខ្ពស់ដែលមានបទពិសោធន៍ក្នុងការចរចាកិច្ចព្រមព្រៀងនេះ។ ខាងក្រោមនេះជាលទ្ធផលសង្ខេបនៃបទបង្ហាញទាំងបី និងកិច្ចពិភាក្សា ដែលជះឥទ្ធិពលលើសេដ្ឋកិច្ចកម្ពុជា៖

### ក. បទបង្ហាញទី១៖ ផលបច្ច័យ និងបញ្ហាប្រឈមនៃកិច្ចព្រមព្រៀងអាសិប

ក្នុងបទបង្ហាញនេះ អ្នកជំនាញលើកឡើងអំពីកិច្ចព្រមព្រៀងអាសិបដែលជាកាតាលីករក្នុងការជំរុញសមាហរណកម្មតំបន់ ខណៈដែលតំបន់អាស៊ាននិងអាស៊ីបូព៌ាបានចាប់ផ្ដើមចាប់យកនិន្នាការសមាហរណកម្មចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ

១៩៨០ មកម្ល៉េះ។ បទបង្ហាញនេះ បានពិភាក្សាអំពីផលប៉ះពាល់ដែលជាផលបច្ច័យនៃកិច្ចព្រមព្រៀងអាសិបមកលើសមាហរណកម្មតំបន់អាស៊ីរួមទាំងអាស៊ានផងដែរ។ ជាលទ្ធផល បទបង្ហាញនេះមានខ្លឹមសារសង្ខេបដូចខាងក្រោម៖

- ការសម្លឹងឃើញរបបពាណិជ្ជកម្មថ្មី ដែលកំណត់ការធ្វើកិច្ចសហប្រតិបត្តិការរវាងប្រទេសជាសមាជិកនៃកិច្ចព្រមព្រៀងនេះសម្រាប់ជាដំណោះស្រាយចំពោះនិន្នាការនៃការអនុវត្តកិច្ចគាំពារនិយម ដែលកើតឡើងពីវិបត្តិជម្ងឺរាតត្បាតកូវីដ-១៩ និងនិន្នាការថ្មីៗផ្សេងទៀតដែលប្រទេសមួយចំនួនប្រកាន់យកពេលជួបបញ្ហាទាក់ទងនឹងសេដ្ឋកិច្ចពិភពលោកនាពេលបច្ចុប្បន្ន។ ដូចនេះ កិច្ចព្រមព្រៀងអាសិបនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហាគាំពារនិយមនៅក្នុងសេដ្ឋកិច្ចសកល និងជាមធ្យោបាយសម្រាប់ជំរុញការធ្វើសមាហរណកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសជាសមាជិក។
- ស្ថិតក្នុងដំណាក់កាលនៃការស្តារសេដ្ឋកិច្ចឡើងវិញ និងការរស់នៅក្នុងប្រក្រតីភាពថ្មីនៃជម្ងឺកូវីដ-១៩ ខ្សែច្រវាក់តម្លៃសកលគឺជាដំណោះស្រាយដ៏ប្រសើរមួយសម្រាប់ផ្តល់ផលប្រយោជន៍ដល់ប្រទេសជាសមាជិក។ កិច្ចព្រមព្រៀងអាសិប បានបង្ហាញនូវអត្ថប្រយោជន៍ និងឥទ្ធិពលវិជ្ជមានសម្រាប់ប្រទេសសមាជិក ជាពិសេសកម្ពុជាដែលជាប្រទេសទទួលបានផលប្រយោជន៍ធំជាងគេទី៣ ពីកិច្ចព្រមព្រៀងនេះ ព្រមទាំងបង្ហាញនូវបញ្ហាប្រឈមមួយចំនួនដែលកម្ពុជានិងសមាជិកដទៃទៀតនឹងរួមគ្នាដោះស្រាយក្រោមកិច្ចព្រមព្រៀងនេះ។
- កិច្ចព្រមព្រៀងអាសិបក៏បានបង្ហាញផងដែរនូវបញ្ហាប្រឈមសំខាន់ៗ ហើយក៏ផ្តល់នូវដំណោះស្រាយចំពោះប្រទេសជាសមាជិកនីមួយៗដោយផ្អែកលើដំណាក់កាលនៃការអភិវឌ្ឍរបស់ប្រទេសទាំងនោះ ជាពិសេសចំពោះប្រទេសកម្ពុជា ដែលវាជាដំណាក់កាលមួយក្នុងការជួយជំរុញការចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួចទៅជាប្រទេសកំពុងអភិវឌ្ឍន៍។
- ទន្ទឹមនឹងនេះ កិច្ចព្រមព្រៀងនេះក៏ផ្តល់សារប្រយោជន៍ផងដែរសម្រាប់បង្កើតជាក្រុមរួមមួយនៃបណ្តាប្រទេសអាស៊ាន ដែលនឹងធ្វើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច-ពាណិជ្ជកម្មជាមួយនឹងប្រទេសជាសមាជិកដទៃទៀតក្នុងរូបភាពសម្របសម្រួលដែលអាចផ្តល់ប្រយោជន៍ទៅវិញទៅមក ជាពិសេសការប្រើប្រាស់សន្និកម្មបច្ចេកវិទ្យា ការធ្វើឱ្យមានសេរីភាវូបនីយកម្មពាណិជ្ជកម្មទំនិញនិងសេវាកម្ម និងការវិនិយោគ ការប្រើប្រាស់បណ្តាញផលិតកម្មសកល និងការសម្រួលវិធានមួយចំនួនដែលជាមូលដ្ឋាននៃកិច្ចសម្រួល និងជំរុញពាណិជ្ជកម្ម។

## ២. បទបង្ហាញទី២៖ ផលប៉ះពាល់នៃកិច្ចព្រមព្រៀងអាសិបលើតំបន់អាស៊ីបូព៌ា និងអាស៊ាន

អ្នកជំនាញបានប្រើប្រាស់ម៉ូឌែលសម្រាប់វិភាគ (រួមមាន Computational General Equilibrium) ដែលបង្កើតជាសេណារីយ៉ូផ្សេងៗគ្នា ដើម្បីសិក្សាពីផលប៉ះពាល់នៃកិច្ចព្រមព្រៀងអាសិបលើតំបន់អាស៊ីបូព៌ា និងអាស៊ាន ដែលរួមមានកម្ពុជាផងដែរ។ នៅក្នុងបទបង្ហាញនេះ អ្នកជំនាញបានធ្វើការវិភាគទាំងផ្នែកគុណភាព និងបរិមាណទៅលើផលបច្ច័យដែលជាកំណើនសេដ្ឋកិច្ចដែលពឹងផ្អែកគ្នាទៅវិញទៅមកក្នុងតំបន់រវាងប្រទេសជាសមាជិក ដូចជា ការប្រើប្រាស់ប្រព័ន្ធឌីជីថលនិងស្វ័យប្រវត្តិកម្មក្នុងតំបន់ដែលជាឧបករណ៍ជំរុញកំណើន និងការគាំទ្រផ្នែកសេដ្ឋកិច្ចតាមរយៈជំនួយបច្ចេកទេសសំដៅពន្លឿនការកែទម្រង់វិធានច្បាប់និងហេដ្ឋារចនាសម្ព័ន្ធនានាជាដើម។ បទបង្ហាញនេះក៏មានការប្រៀបធៀបរវាងកិច្ចព្រមព្រៀងអាសិបជាមួយនឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីផ្សេងទៀត ដូចជា កិច្ចព្រមព្រៀងភាពជាដៃគូ

អន្តរប៉ាស៊ីហ្វិកគ្រប់ជ្រុងជ្រោយនិងមានវឌ្ឍនភាព (CPTPP) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្រោមក្របខ័ណ្ឌអាស៊ាន (ASEAN+1 FTAs) ជាដើម។ ជាលទ្ធផល បទបង្ហាញនេះមានខ្លឹមសារសង្ខេបដូចខាងក្រោម៖

- ភាពចាំបាច់នៃការបំពេញឱ្យគ្នាទៅវិញទៅមកក្នុងតំបន់គឺជាកត្តាដ៏សំខាន់ដែលកិច្ចព្រមព្រៀងបានផ្តល់ជូន
- ការប្រើប្រាស់វិធានប្រភពដើមទំនិញ ដែលអនុញ្ញាតឱ្យមានលំហូរវត្ថុធាតុដើមពីប្រទេសជាសមាជិកនៃកិច្ចព្រមព្រៀង និងធ្វើឱ្យប្រទេសជាសមាជិកទទួលប្រយោជន៍កាន់តែច្រើននៅក្នុងការអនុវត្ត និងតួនាទីរបស់ខ្លួនក្នុងខ្សែច្រវាក់តម្លៃនិងខ្សែច្រវាក់ផ្គត់ផ្គង់តំបន់និងសកល។
- បទបង្ហាញក៏បានជម្រាបជូនអំពីបច្ច័យវិជ្ជមានពីការកាត់បន្ថយអត្រាពន្ធគយ កិច្ចសម្រួលពាណិជ្ជកម្មសេវាការពង្រីកបណ្តាញឡូហ្ស៊ីស្ទិក និងការប្តេជ្ញាចិត្តលើវិស័យវិនិយោគដែលធ្វើឱ្យមានការកាត់បន្ថយហានិភ័យដែលរួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់អត្ថប្រយោជន៍ដល់ប្រទេសជាសមាជិកនីមួយៗ ទៅតាមដំណាក់កាលនៃការអភិវឌ្ឍរបស់ប្រទេសរៀងៗខ្លួន។
- កិច្ចព្រមព្រៀងអាសិបផ្តល់ផលចំណេញច្រើនជាងកិច្ចព្រមព្រៀង CPTPP ហើយស្តែងនូវផលប្រយោជន៍កាន់តែប្រសើរឡើងនូវការតភ្ជាប់ចិន-ជប៉ុន-កូរ៉េ ដែលទំនាក់ទំនងនេះនឹងជះឥទ្ធិពលវិជ្ជមានដល់បណ្តាប្រទេសជាសមាជិក ជាពិសេសប្រទេសជាសមាជិកអាស៊ាន។
- ការប្រើប្រាស់វិធានប្រភពដើមទំនិញរួមតែមួយនឹងធ្វើឱ្យមានលំហូពាណិជ្ជកម្មកាន់តែទូលំទូលាយ ដែលនឹងជួយជំរុញដល់ពាណិជ្ជកម្មនិងសេដ្ឋកិច្ចរបស់ប្រទេសជាសមាជិក។

## គ. បទបង្ហាញទី៣៖ កិច្ចព្រមព្រៀងអាសិប ការស្តារសេដ្ឋកិច្ចឡើងវិញពីវិបត្តិជម្ងឺរាតត្បាត និងគោលដៅអភិវឌ្ឍន៍នាពេលអនាគត

ក្នុងបទបង្ហាញនេះ អ្នកជំនាញបានលើកឡើងពីភាពធន់នៃសេដ្ឋកិច្ច និងការធ្វើពិពិធកម្មផលិតផលនិងទីផ្សារសម្រាប់ប្រទេសជាសមាជិកអាសិប។ ជាលទ្ធផល កិច្ចព្រមព្រៀងអាសិបនឹងផ្តល់ប្រយោជន៍ចំពោះការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិកូវីដ-១៩ និងបរិវត្តកម្មតំបន់ តួយ៉ាង កិច្ចព្រមព្រៀងអាសិបនឹងចូលរួមចំណែកបង្កើនពាណិជ្ជកម្មសេវា (នឹងកើនឡើងច្រើនជាង ៣០% នៅឆ្នាំ២០៤០) ការធ្វើពាណិជ្ជកម្មនិងវិនិយោគផ្អែកលើវិធានច្បាប់ ការបើកច្រកទីផ្សារបន្ថែម ការពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចកាន់តែស៊ីជម្រៅ ការពង្រឹងមជ្ឈភាពអាស៊ាន និងភាពបត់បែនក្នុងការពិនិត្យនិងពិភាក្សាបន្ថែមលើខ្លឹមសារណាមួយ (Living Agreement) នៃកិច្ចព្រមព្រៀងនេះ។

អ្នកជំនាញក៏បានពន្យល់ពីមាត្រាសំខាន់ៗដែលបញ្ចូលជាគុសក្តានុពល រួមមាន ពាណិជ្ជកម្មឌីជីថល វិធានប្រភពដើមទំនិញ អនាម័យ-ភូតគាមអនាម័យ ស្តង់ដារ ការអភិវឌ្ឍវិស័យឯកជន ព្រមទាំងការប្រើប្រាស់បញ្ជីអវិជ្ជមាន (Negative List) នៅក្នុងការប្តេជ្ញាចិត្តផ្នែកពាណិជ្ជកម្មសេវាផងដែរ។

## ឃ. កិច្ចពិភាក្សាដេញដោលស្តីពីសេដ្ឋកិច្ចកម្ពុជា

កិច្ចពិភាក្សានេះ មានការចូលរួមពីវាគ្មិនជាមន្ត្រីជំនាញជាន់ខ្ពស់កម្ពុជា និងជាប្រធានចរចាកិច្ចព្រមព្រៀងអាសិបព្រមទាំងមន្ត្រីជាន់ខ្ពស់របស់សភាពាណិជ្ជកម្មកម្ពុជា។ ក្នុងកិច្ចពិភាក្សានេះ មន្ត្រីជំនាញបានលើកឡើងពីផលប្រយោជន៍ដែលកិច្ចព្រមព្រៀងអាសិបអាចផ្តល់ឱ្យកម្ពុជា រួមមាន៖

- ការទទួលបានច្រកទីផ្សារបន្ថែមលើកិច្ចព្រមព្រៀងដែលកម្ពុជាមានជាមួយប្រទេសដៃគូទាំងប្រាំ (ចិន ជប៉ុន កូរ៉េខាងត្បូង អូស្ត្រាលី និងនូវែលសេឡង់) ក្រោមក្របខ័ណ្ឌអាស៊ាន (ASEAN+1 FTAs) ដែលក្នុងនោះ កម្ពុជាទទួលបាន ៩៥,៧០% ពីអូស្ត្រាលី; ៨៥% ពីចិន; ៩៩,៦៥% ពីជប៉ុន; ៨៨% ពីកូរ៉េខាងត្បូង និង ៩៧,៣៥% ពីនូវែលសេឡង់ ។ ការណ៍នេះនឹងជួយជំរុញកំណើនការនាំចេញប្រចាំឆ្នាំរបស់កម្ពុជាប្រមាណ ៧,៣%។
- វិធានប្រភពដើមទំនិញកម្ពុជាមានភាពបត់បែន និងមានជម្រើសច្រើនក្នុងការប្រើប្រាស់។
- ការទទួលបានការវិនិយោគបរទេសច្រើន ដោយសារកម្ពុជាជាទីតាំងភូមិសាស្ត្រត្រង់ចំណុចកណ្តាលនៃតំបន់អាស៊ាន ដែលគេរំពឹងថានឹងមានកំណើនប្រចាំឆ្នាំប្រមាណ ២៣,៤%។
- ការទទួលបានក្របខ័ណ្ឌពង្រឹងសេដ្ឋកិច្ចថ្មីស្របពេលកម្ពុជាបានត្រៀមខ្លួនរួចរាល់ បន្ទាប់ពីរាជរដ្ឋាភិបាលយកឈ្នះការគំរាមកំហែងខ្លាំងពីជម្ងឺកូវីដ-១៩ តាមរយៈយុទ្ធនាការចាក់វ៉ាក់សាំងកន្លងមក ។ល។
- កិច្ចព្រមព្រៀងអាសិបនឹងជួយជំរុញកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំរបស់កម្ពុជាប្រមាណ ២% លើកំណើនដែលមានស្រាប់។

ទោះជាយ៉ាងណា វាគ្មិនបានលើកឡើងពីគោលនយោបាយមួយចំនួនដែលកម្ពុជាត្រូវអនុវត្ត ដើម្បីទទួលបានអត្ថប្រយោជន៍អតិបរមាពីកិច្ចព្រមព្រៀងអាសិប។ គោលនយោបាយនោះ រួមមាន ការបន្តរក្សាការកែទម្រង់ទីផ្សារ ការពង្រឹងសកម្មភាពឧស្សាហកម្មក្នុងស្រុក ការទាញយកផលប្រយោជន៍ចេញពីការតភ្ជាប់ពាណិជ្ជកម្មរវាងចិន-ជប៉ុន-កូរ៉េខាងត្បូង ការធ្វើពិពិធកម្មផលិផលនាំចេញជាជាងពឹងផ្អែកតែលើវិស័យវាយនភណ្ឌនិងសម្លៀកបំពាក់ ការពង្រឹងសមត្ថភាពផ្នែកសេវាកម្មឡជីថលនិងតាមប្រព័ន្ធអេឡិចត្រូនិក ការពង្រឹងកិច្ចសម្រួលពាណិជ្ជកម្ម ការគាំទ្រសហគ្រាសធុនតូចនិងមធ្យម និងការអភិវឌ្ឍជំនាញ (រឹងនិងទន់) ។ល។

គួររំឭកផងដែរ កិច្ចព្រមព្រៀងអាសិប ជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដ៏ធំផុតលើសកលលោក គ្របដណ្តប់លើប្រជាជនប្រមាណ ៣០% នៃប្រជាជនពិភពលោក ផលិតផលក្នុងស្រុកសរុបតំបន់ប្រមាណ ៣០% នៃផលិតផលក្នុងស្រុកសរុបសកល និងប្រមាណ ២៨% នៃពាណិជ្ជកម្មសកល។ កិច្ចព្រមព្រៀងអាសិបត្រូវបានផ្តើមការចរចានៅប្រទេសកម្ពុជាក្នុងឆ្នាំ២០១២ និងបានចាប់ផ្តើមចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២២៕

ថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២

សូមស្កេនទីនេះដើម្បីទាញយកឯកសារ៖

សៀវភៅអាសិប

ឯកសារបទបង្ហាញ